**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សន្និសីទសារព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី បច្ចុប្បន្នភាពជំងឺកូវីដ-១៩ នៅកម្ពុជា គិតត្រឹមម៉ោង ០៧:០០ ព្រឹក ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០ បង្ហាញថា មានករណីព្យាបាលជាសះស្បើយ ០២នាក់ និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នោះទេ។ ដូច្នេះ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

– **អ្នកព្យាបាលជាសះស្បើយ** ចំនួន **១០៧នាក់** ( ស្មើនឹង ៨៧,៧០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ៣០នាក់ និងបុរស ៧៧នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្ត្រីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិប៊ែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៨នាក់ (ក្នុងនេះ មានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ២០នាក់ បុរសជនជាតិកាណាដា ០១នាក់ បុរសជនជាតិម៉ាឡេស៊ី១២នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ ស្ត្រីជនជាតិវៀតណាម ០១នាក់ បុរសជនជាតិខ្មែរ ៣៩នាក់ និងស្ត្រីជនជាតិខ្មែរ ០៥នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។

– **អ្នកដែលកំពុងសម្រាកព្យាបាល** សរុបនៅសល់ចំនួន **១៥នាក់** (ស្ត្រី ០៨នាក់ និងបុរស ០៧នាក់)នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

– **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១២២នាក់** (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។

## ២. ករណីជាសះស្បើយ ៖ ចំនួន ០២នាក់

- បុរសជនជាតិខ្មែរ អាយុ ៤៨ឆ្នាំ រស់នៅភូមស្វាគីធី២ សង្កាត់រតនៈ ក្រុងបាត់ដំបង (ជាអ្នកដែលបានវិលត្រឡប់មកពីពិធីសាសនានៅប្រទេសម៉ាឡេស៊ី) បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតអោយចេញពីមន្ទីរពេទ្យខេត្តបាត់ដំបង។
- បុរសជនជាតិបារាំងអាយុ ៦៥ឆ្នាំ ជាភ្ញៀវទេសចរក្រុមបារាំងមកលេងនៅក្រុងព្រះសីហនុ បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបាន



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ... ៨៨៤ ៩០៥

អនុញ្ញាតឲ្យចេញពីបន្ទប់ព្យាបាលទៅស្នាក់នៅបន្ទប់មួយទៀតក្នុងសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ រង់ចាំជើងហោះហើរវិលត្រឡប់ទៅប្រទេសបារាំងវិញ ។

**៣. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី** នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០។

**៤. ចំនួនសរុបវត្ថុសំណាកដែលបានធ្វើវិភាគ** ទាំងអស់មានចំនួន ៩,៧៩២សំណាក សម្រាប់ទូទាំងប្រទេស (**គិតចាប់តាំងពីខែមករា ឆ្នាំ២០២០ មកដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០**) ដែលក្នុងចំណោមប្រជាជនមួយលាននាក់ កម្ពុជាបានធ្វើវិភាគវត្ថុសំណាកបានចំនួន ៦១២សំណាក ហើយចំនួននេះ បានបង្ហាញថាកម្ពុជាបានអនុវត្តការធ្វើតេស្តរកវីរុសកូវីដ-១៩ បានច្រើនជាងបណ្តាប្រទេសក្នុងអាស៊ានមួយចំនួន ដូចជា៖

- ប្រទេសភូមា មានចំនួន ៧៦សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់
- ប្រទេសឡាវមានចំនួន ១៨១សំណាក ក្នុងចំណោមប្រជាជន មួយលាននាក់
- ប្រទេសឥណ្ឌូណេស៊ី មាន ១៤៤សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់
- ប្រទេសហ្វីលីពីន មានចំនួន ៥១១សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់ ។

ក្រសួងសុខាភិបាល សូមធ្វើការកត់សម្គាល់ថា ស្ថានភាពជំងឺកូវីដ-១៩ នៅពេលនេះ ប្រឹត្បិតតែក្នុងរយៈពេលមួយសប្តាហ៍កន្លងមកនេះ មិនមានរកឃើញអ្នកឆ្លងវីរុសកូវីដ-១៩ និងមានអ្នកជំងឺបានព្យាបាលជាសះស្បើយជាបន្តបន្ទាប់ (មិនមានស្លាប់) ក៏ពិតមែន ក៏ប៉ុន្តែ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ បង្កើន និងបន្តការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវនិងត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត ហើយត្រូវខិតខំអនុវត្តគ្រប់បែបយ៉ាងទាំងអស់ តាមបទបញ្ជារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការណែនាំនានារបស់ក្រសួងសុខាភិបាល ដើម្បីកុំឱ្យមានការចម្លងរាតត្បាតចូលក្នុងសហគមន៍ ជាពិសេស ត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ដោយមិនត្រូវធ្វើដំណើរជួបជុំគ្នាច្រើន ឬបើចាំបាច់ខានមិនបាននោះ ក៏ត្រូវកាត់បន្ថយឲ្យបានជាអតិប្បរិមានូវការធ្វើដំណើរចល័តរបស់បុគ្គលពីកន្លែងមួយទៅកន្លែងមួយ ក្រោយពេលចូលឆ្នាំប្រពៃណីជាតិខ្មែរនេះ។ ទន្ទឹមនឹងនោះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចេះផ្លាស់ប្តូរឥរិយាបទ និងទម្លាប់របស់ខ្លួន ដូចជាការអនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួននូវអនាម័យដៃស្អាត ដោយលាងសម្អាតជាមួយទឹកស្អាតនឹងសាប៊ូ ឬអាល់កុល ឬទឹកដែលលាងដៃ ឲ្យបានញឹកញាប់ ចៀសវាងការជួបជុំគ្នាច្រើនកុះករ ក្នុងស្ថានភាពជំងឺកូវីដ-១៩ ដែលកំពុងតែរាលដាលជាសកល។

បន្ថែមលើនេះ ចំពោះបងប្អូនដែលបានសម្រុកធ្វើដំណើរទៅស្រុកកំណើតមុនពេលចូលឆ្នាំប្រពៃណីជាតិខ្មែរ ហើយត្រូវវិលត្រឡប់មកលំនៅដ្ឋាន ឬមកចូលធ្វើការនៅតាមទីកន្លែង រោងចក្រ សហគ្រាស ក្រសួង ស្ថាប័ន ឬមន្ទីរៀងៗខ្លួននោះ ត្រូវអនុវត្តនូវវិធានការតាមដានសុខភាពផ្ទាល់ខ្លួន ដោយដាក់ខ្លួនឲ្យនៅដាច់ដោយឡែកចំនួន ១៤ថ្ងៃ ឬអាចធ្វើការពីផ្ទះតាមអនឡាញបានក្នុងរយៈពេលធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃនេះ។ ការរឹតបន្តឹង និងការផ្អាកការធ្វើដំណើរមកពីប្រទេសចំនួន ០៦ប្រទេស មានប្រទេសអ៊ីតាលី អេស្ប៉ាញ អាល្លឺម៉ង់ អាមេរិក បារាំង និងអ៊ីរ៉ង់ ត្រូវបានពន្យាពេល និងបន្តធ្វើរហូតដល់ស្ថានភាពរាតត្បាតជំងឺកូវីដ-១៩មានការធូរស្រាល ក្រោយពីមានការវាយតម្លៃរួមគ្នារវាងក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក។

សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ បន្តគោរពតាមការអំពាវនាវរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានសរសេរណែនាំនៅក្នុងទំព័រហ្វេសបុករបស់ **សម្តេចតេជោ** នាពេលថ្មីៗកន្លងទៅនេះ ដែលជាសារច្រើន



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ០៨៤ ៩០៩

វិលើកដ៏មានសារប្រយោជន៍ជាទីបំផុត សម្រាប់សុខភាពប្រជាជនខ្មែរទៅបានជៀសផុតពីការចម្លងវីរុសកូវីដ-១៩ ជាពិសេស សូមឲ្យបន្តចូលរួមការពារទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដោយ **សម្តេចតេជោ** បានណែនាំដ៏ខ្ពង់ខ្ពស់ថា៖

*"ទោះបីពេលនេះ ប្រទេសយើងគ្មានការដាក់បម្រាមហាមឃាត់តឹងតែងក្នុងការធ្វើដំណើរពីខេត្តមួយទៅកាន់ខេត្តមួយក្តី បងប្អូនប្រជាពលរដ្ឋត្រូវតែមានការប្រុងប្រយ័ត្នយកចិត្តទុកដាក់ចំពោះសុវត្ថិភាពសុខភាពជាប្រចាំ ហើយត្រូវចងចាំគ្រប់ពេលថា ជំងឺឆ្លងកូវីដ-១៩ គឺជាជំងឺឆ្លងរាតត្បាតដ៏កាចសាហាវបំផុត ដែលក្នុងតែមួយប៉ព្រិចភ្នែក ប៉ុណ្ណោះវាអាចបង្កវិនាសកម្មបានយ៉ាងឆាប់រហ័សបំផុត។*

*មកទល់ពេលនេះ គ្មានថ្នាំលេបឬចាក់ព្យាបាលនៅឡើយទេ។ សូមបងប្អូនប្រជាពលរដ្ឋយកជាប់ជាមួយនូវម៉ាស, ទឹកអាល់កុល ឬទឹកដែលសម្លាប់មេរោគនិងបាក់តេរី ហើយឧស្សាហ៍ផុសលាងសម្អាតដៃជាប្រចាំ។*

*សូមកុំអោយមានការសោកស្តាយធ្លាក់មកលើខ្លួនយើង និងក្រុមគ្រួសារយើងអោយសោះ ដោយសារតែការធ្វេសប្រហែស និងមើលស្រាល ជំងឺឆ្លងកូវីដ-១៩។ យើងចូលរួមទប់ស្កាត់ការឆ្លងរាលដាលមេរោគកូវីដ-១៩ ដោយស្តាប់តាមការណែនាំរបស់ក្រសួងសុខាភិបាល" ។*

ដើម្បីបន្តទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ក្រសួងសុខាភិបាល នឹងបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការដាក់នៅដាច់ដោយឡែក ការធ្វើតេស្ត ការព្យាបាល និងការតាមរកអ្នកដែលប៉ះពាល់ ដោយហ្មត់ចត់ជាទីបំផុត (Isolate-Test-Treat-Trace) ដែលជាការណែនាំរបស់អង្គការសុខភាពពិភពលោក ។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាដែលខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុតក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីវីរុសកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាពតាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងមកក្រសួងសុខាភិបាល តាមទូរស័ព្ទលេខ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ [illegible] ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

*សំគាល់៖ អ្នកជំងឺពីខេត្តកែប ចំនួន ០១នាក់ បានបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

*សំគាល់៖ អ្នកជំងឺពីខេត្តកែប ចំនួន ០១នាក់ បានប្ដូរមកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*